**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៣៤៩៧ សហវ.ហក

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩

**គោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

**កម្មវត្ថុ:** សំណើមានវិធានការត្បិតត្បៀត សន្សំសំចៃ ដើម្បីកាត់បន្ថយចំណាយដំណើរការរដ្ឋបាល។

**យោង:** -ព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩

-សារាចរលេខ ០០៥ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការណែនាំលើការអនុវត្ត ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩

-កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២

-ការណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៩

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ពិសេសបន្ទាប់ពីបានទទួលការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តម មេត្តាជ្រាបថា ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចកម្ពុជាកំពុងរងផលប៉ះពាល់ពីវិបត្តិនៃកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងឱនភាពសេដ្ឋកិច្ចសាកលលោក ដើម្បីរក្សាបាននូវស្ថានភាពម៉ាក្រូសេដ្ឋកិច្ច រក្សាបាននូវអធិបតីតេយ្យភាព ប្រសិទ្ធភាពចំណាយថវិកា និងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមស្នើឯកឧត្តម ក្នុងនាមជាអាណាប័កដើមខ្សែ និងជាអាណាប័កតាមការប្រទានសិទ្ធ មេត្តាលែលក*ចាត់វិធានការណ៍សន្សំសំចៃ និងគ្រប់គ្រងចំណាយឱ្យមានប្រសិទ្ធភាពខ្ពស់បំផុតក្នុងកិច្ចដំណើការរដ្ឋបាល* ដូចជា៖

▪*ចំណាយលើការប្រើប្រាស់ប្រេងឥន្ធនៈ:* ៖ ត្រូវគ្រោងគិតឱ្យបានត្រឹមត្រូវតាមចំនួនរថយន្ត និងមធ្យោបាយយានយន្តផ្សេងទៀត ដែលមានចុះក្នុបញ្ជីសារពើភ័ណ្ឌពិតប្រាកដ និងកំពុងដំណើរការជាក់ស្តែង។រថយន្តផ្ទាល់ខ្លួនអនុញ្ញាត ឱ្យគ្រោងចូលចំពោះតែរថយន្តរបស់មន្ត្រីថ្នាក់ដឹកនាំចាប់ពីថ្នាក់អគ្គនាយក ឬអគ្គលេខាធិការឡើង ដែលមិនមានមធ្យោបាយរបស់រដ្ឋប្រាស់ប្រើ ។ រីឯមន្ត្រីជាប់កិច្ចសន្យា ឬទីប្រឹក្សាដែលមានឋានៈស្មើ មិនអនុញ្ញាត្តជូនឡើយ។ ចំពោះគម្រោងចំណាយទិញប្រេងឥន្ធនៈត្រូវបន្តអនុវត្តតាមបរិមាណដែលបានកំណត់បណ្តោះអាសន្នកន្លង មកដោយផ្អែកលើថ្លៃប្រេងលើទីផ្សារបច្ចុប្បន្ន។

▪ *អគ្គិសនី ទឹក និងទូរស័ព្ទ* ៖ កាត់បន្ថយ និងសន្សំសំចៃឱ្យស្ថិតក្នុងកម្រិតមួយសមស្រប និង ចាំបាច់ ដោយត្រូវកាត់បន្ថយជាអាតិបរមានូវការប្រើប្រាស់ទាំងឡាយណាដែលមិនបម្រើ ផលប្រយោជន៍របស់ក្រសួង-ស្ថាប័ន ។

▪ *សម្ភារៈការិយាល័យ សម្ភារៈបរិក្ខារប្រើប្រាស់ និងគ្រឿងសង្ហារឹម* - ត្រូវសុំចំណាយតែក្នុងករណីចាំបាច់ ដូចមានការប្រែប្រួលមន្ត្រីរាជការ ឬត្រូវបំពាក់សម្ភារៈឱ្យអង្គភាពទើបបង្កើតថ្មី ។ ចំពោះគ្រឿងសង្ហារឹមរបស់ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ក៏មិនត្រូវឱ្យលក្ខណៈទំនើបហួស ហេតុពេកទេ ។

▪*ការជួសជុលអាគារ និងសាងសង់ថ្មី* - ត្រូវផ្អាកជាបណ្តោះអាសន្ននូវការសាងសង់ថ្មី និងជួសជុលអាគារគ្រប់ប្រភេទ លើកលែងតែក្នុងករណីដែលអាគារនោះមានភាពទ្រុឌទ្រោមខ្លាំងដែលត្រូវការជួសជុលជាបន្ទាន់ ។

▪*ការទទួលភ្ញៀវ និងបដិសណ្ឋារកិច្ច* - មិនត្រូវមានភាពហ៊ឺហា គគ្រឹកគគ្រេងហួសហេតុហើយចំណាយត្រូវឱ្យស្របតាមរបបកំណត់ ដូចជារបបបេសកម្ម និងស្នាក់នៅជាដើម ។

▪*បេសកម្មក្នុង និងក្រៅប្រទេស* -គួរគប្បីធ្វើអាទិភាពភាវូបនីយកម្មបេសកម្ម ដោយត្រូវផ្អាកលុបចោលនូវបេសកម្មណាដែលមិនចាំបាច់ឬដែលអាចជំនួសបានដោយស្ថានតំណាងរបស់ប្រទេសកម្ពុជានៅប្រទេសដែលត្រូវបំពេញបេសកម្មនោះ ។ ម្យ៉ាងទៀត គួរខិតខំកាត់បន្ថយឱ្យនៅជាអាប្បបរមានូវចំនួនសមាជិកប្រតិភូដែលត្រូវចូលរួម។របបបេសកម្មគប្បីជូនចំពោះតែមន្ត្រីណាដែលមានឋានន្តរស័ក្តិពិតប្រាកដនៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័នរដ្ឋប៉ុណ្ណោះដោយមិនរួមបញ្ចូលនូវបុគ្គលិកជាប់កិច្ចសន្យា ឬទីប្រឹក្សាដែលមានឋានៈស្មើឡើយ ។

▪ *ការទិញរថយន្ត* -ត្រូវផ្អាកការចំណាយនេះ លើកលែងតែមានការសម្រេចដោយឡែកពីរាជរដ្ឋាភិបាល ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹម និងជឿជាក់យ៉ាងមុតមាំលើស្មារតីទទួលខុសត្រូវរបស់ឯកឧត្តម ក្នុងនាមជាអ្នកអាណាប័កដើមខ្សែ ឬជាអាណាប័កតាមការប្រទានសិទ្ធិ ក្នុងការដាក់ចេញនូវវិធានការអនុវត្តជាក់ស្តែងឱ្យបានជោគជ័យ តាមគោលការណ៍នយោបាយសន្សំសំចៃដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមាន ប្រសិទ្ធភាព ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

<u>ចម្លងជូន</u> ៖
-ក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អាជ្ញាធរសេវនកម្មជាតិ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា«ដើម្បីជ្រាបជារបាយការណ៍»
-អង្គភាពពាក់ព័ន្ធចំណុះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ឯកសារ-កាលប្បវត្តិ

វាយអត្ថបទដោយ ៖ លោក ឈឹម ទីណា